ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៨ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាយសេងបាវិត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

www.pheakdeylaw.com

- **បានឃើញអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស តាយសេងបាវិត**
- **បានឃើញសេចក្តីជូនដំណឹងលេខ ២៦៨ សជណ.សរ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃសម័យប្រជុំច្រកចេញ-ចូលតែមួយនៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**
- **យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

សម្រេច

ប្រការ ១.-

បង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាយសេងបាវិត ដែលមានទីតាំងស្ថិតនៅឃុំច្រកម្ទេស ស្រុកស្វាយទាប និងឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដែលមានសមាសភាពដូចខាងក្រោម :

១-តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា	ប្រធាន
២-តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៣-តំណាងទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៤-តំណាងនាយកដ្ឋានត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម	សមាជិក
៥-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក

សមាជិករដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ២.- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់ ។ អនុវត្តការត្រួតពិនិត្យបែបបទគយ សំរាប់ការចេញចូលទំនិញ និងសំរួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល ។
- ត្រួតពិនិត្យ ការអនុវត្តន៍ការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។

www.pheakdeylaw.com

- ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូនទូវការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសំរេចជូនអ្នកវិនិយោគក្នុងតំបន់ នៅនឹងកន្លែង ។
- ធ្វើការត្រួតពិនិត្យការងារ សកម្មភាពតាមមុខជំនាញនៅក្នុងតំបន់ ។
- សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។
- សំរួលរាល់បែបបទ ដែលពាក់ព័ន្ធ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពីសកម្មភាពរបស់តំបន់ជូនក្រសួង-ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសំរបសំរួល ដោះស្រាយរាល់សំណើរបស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង-ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

ប្រការ ៣.- គ្រប់តំណាងក្រសួង-ស្ថាប័ន ដែលបំពេញភារកិច្ចនៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាយសេង បាវិត ដូចមានចែងក្នុងប្រការ ១ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុន តាយ សេង បាវិត អេសអ៊ីហ្សិត ខូអិលធីឌី មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com